# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជា១០ឆ្នាំនៃការិយាល័យយុវជន
# ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨
## *ខ្ញុំជាអ្នកបម្រើ ជាចរិតធម្មជាតិរបស់ខ្ញុំ*

អត្ថបទទី១៖ ១សល ១,១៨-២៥
ដំណឹងល្អ៖ មក ១០,៣២-៤៥

បងប្អូនជាទីស្រឡាញ់!

ព្រះយេស៊ូកំពុងនិយាយរឿងសំខាន់ណាស់ ជិតដល់ពេលវេលាត្រូវស្លាប់ ជិតដល់ពេលវេលារងទុក្ខលំបាក ជិតចូលដល់វេលាពិបាក ក្រុមគ្រីស្តទូត មិនរវីរវល់សោះ និយាយរឿងផ្សេង អ្នកណាធំជាងគេ អ្នកណាអង្គុយខាងស្តាំ អ្នកណាអង្គុយខាងឆ្វេង។

ខ្ញុំចង់និយាយ១០ឆ្នាំខាងមុខទៀត សម្រាប់ការិយាល័យយុវជន។ តើ១០ឆ្នាំខាងមុខនេះយើងធ្វើអ្វីខ្លះ? ឲ្យចេញអត្តទស្សនៈ ដើម្បីឲ្យយើងទៅមុខសម្រាប់១០ឆ្នាំទៀត។ ប្រហែលអត្តទស្សនៈសំខាន់ ដែលយើងត្រូវទទួលនៅក្នុងរបៀបដែលយើងធ្វើការជាប្រធានយុវជន នៅក្នុងរបៀបដែលយើងណែនាំប្រធានយុវជន របៀបដែលយើងណែនាំយុវជន និងកុមារ គឺព្រះបន្ទូលរបស់ព្រះយេស៊ូថ្ងៃនេះ "**ផ្ទុយទៅវិញបើមានម្នាក់ចង់ធ្វើធំជាងគេ ក្នុងចំណោមអ្នករាល់គ្នា ត្រូវឲ្យគេបម្រើអ្នករាល់គ្នា។ ក្នុងចំណោមអ្នករាល់គ្នា បើចង់ធ្វើជាមេគេ ត្រូវធ្វើជាទាសកររបស់គេគ្រប់គ្នាសិន ត្បិតបុត្រមនុស្សមកក្នុងពិភពលោកនេះ មិនមែនដើម្បីឲ្យគេបម្រើលោក គឺដើម្បីឲ្យលោកបម្រើគេ។**" យប់នេះ ណែនាំឲ្យយើងផ្ទាល់ខ្លួនជាអ្នកបម្រើ ប៉ុន្តែណែនាំឲ្យមេក្រុមយុវជន មេក្រុមកាយឫទ្ធិ និងយុវជនយើងទាំងអស់ កុមារយើងទាំងអស់ ឲ្យមានចិត្តបម្រើ។ ពេលយើងស្តាប់នៅក្នុងវប្បធម៌ ទម្លាប់និយាយ យើងប្រើពាក្យអី គឺប្រើ លោកឪពុកប្រើ មេប្រើ លោកគ្រូប្រើ។ ប៉ុន្តែ ព្រះយេស៊ូអត់ដែលប្រើពាក្យនេះ ព្រះអង្គនិយាយថា យើងជាអ្នកបម្រើ ដែលទៅជាចរិតធម្មជាតិ «**ខ្ញុំជាអ្នកបម្រើ ជាចរិតធម្មជាតិរបស់ខ្ញុំ**»។ ពេលខ្ញុំឃើញសំរាមមួយ ពេលខ្ញុំឃើញអ្វីមួយដែលខុសឆ្គង ភ្លាមខ្ញុំមិនគិតឲ្យគេប្រើខ្ញុំ ខ្ញុំមិនគិតឲ្យគេបញ្ជាខ្ញុំ ខ្ញុំទៅធ្វើ។ ដូច្នេះ យើងជាមេ ត្រូវការគិត ដើម្បីឲ្យកូនក្មេងនិងយុវជនចូលទៅក្នុងនេះ។ ប្រសិនបើយុវជននិងកូនក្មេងដែលយើងទទួល ទោះបីគេមិនមែនគ្រីស្តបរិស័ទ គេចូលនៅក្នុងវប្បធម៌ថ្មីនេះ ខ្ញុំជាអ្នកបម្រើមានអត្ថន័យថា ខ្ញុំជាអ្នកជួយ ខ្ញុំមានចិត្តអាណិតមេត្តា ខ្ញុំជាអ្នកយល់ចិត្តបងប្អូនឯទៀតៗ សង្គមរបស់យើងបន្តិចម្តងៗប្លែក។ ខ្ញុំមិនធ្វើអ្វីបានរង្វាន់ ខ្ញុំមិនធ្វើអ្វីបានលុយ ខ្ញុំធ្វើអ្វីខ្លះបានឬមិនបាន គឺខ្ញុំធ្វើអស់ពីចិត្តរបស់ខ្ញុំ យើងត្រូវការនេះ។

ពេលយើងមានកូន បង្រៀនកូនឲ្យចេះធ្វើជាអ្នកបម្រើ បម្រើត្រឹមត្រូវ មិនមែនឪពុកម្ដាយត្រូវការធ្វើទាំងអស់ ប្រហែលរៀបចំកន្ទេលឬមុង ព្រឹកឡើងរៀបគ្រែ ទុកឲ្យគាត់ធ្វើផ្ទាល់ខ្លួនកន្លែងគាត់ ឲ្យគាត់ធ្វើ បើមិនអីចឹងគាត់អត់ចេះធ្វើអ្វីទាំងអស់។ ពេលហូបបាយហើយ ឲ្យកូនលើកម្ហូប ជួយលាងចាន។ នៅព្រឹកនេះ ព្រះយេស៊ូមានព្រះបន្ទូលថា "**ចាប់ពីពេលនេះតទៅ បងប្អូន ជាអ្នកបម្រើ ជាមិត្តសម្លាញ់របស់ខ្ញុំ**"។ ដូច្នេះពេលយើងធ្វើជាអ្នកបម្រើ យើងភ្ជាប់ជាមួយមិត្តភាពព្រះយេស៊ូ ដោយសារជារបៀបរបស់ព្រះយេស៊ូ។ ដូច្នេះនេះអាចនិយាយថា ទៅជាពាក្យស្លោក អត្តទស្សនៈដល់កំពូលធ្វើយ៉ាងម៉េចដើម្បីបម្រើ។ បម្រើ ដើម្បីចូលក្នុងជីវិតនៃព្រះសហគមន៍ ប៉ុន្តែចូលនៅក្នុងសង្គមដែរ។ នៅសង្គមសព្វថ្ងៃ ខ្ញុំគិតថាខ្វះអ្នកបម្រើ ដោយសារយើងមានចិត្តអាត្មានិយម យើងមានចិត្តលោភលន់។ ដូច្នេះអាត្មានិយម និងលោភលន់នាំឲ្យយើងមិនចង់បម្រើអ្នកដទៃ ព្រោះអត់មានផលប្រយោជន៍។ ខ្ញុំសូមនិយាយសម្រាប់១០ឆ្នាំខាងមុខ ឲ្យកម្មវិធីយុវជនទៅជាការិយាល័យ អប់រំចិត្ត អប់រំកាយ និងផ្លូវវិញ្ញាណ។

យើងមានសមត្ថភាពច្រើនដើម្បីរៀបចំកាលវិភាគ ដើម្បីរៀបចំសិក្ខាសាលា ដើម្បីរៀបចំបរិយាកាស។ អ្នកទទួលខុសត្រូវ ត្រូវតែចេះចែកកិច្ចការងារ តួនាទី រៀបចំផ្កា ម្ហូបអាហារ រៀបចំភ្លើង រៀបចំភ្លេង រៀបចំឯកសារ រៀបចំក្រដាស រៀបចំសៀវភៅ រៀបចំកន្លែង។ ១០ឆ្នាំខាងមុខឲ្យយើងទៅជាអ្នកដែលចូលការអប់រំយ៉ាងជ្រៅ។ ឲ្យប្រធានបទដែលយើងរើសទៅជាម្ហូបអាហារដើម្បីចិញ្ចឹមកូនក្មេង ជំទង់និងយុវជន។ ចិញ្ចឹមជីវិតគេតាមផ្លូវកាយ ផ្លូវចិត្ត និងផ្លូវវិញ្ញាណ ដោយសារយើងដឹងថាយើងអត់មានតែគ្រីស្តបរិស័ទ យើងមានពុទ្ធបរិស័ទដែរ។ ឲ្យយើងចូលយ៉ាងជ្រៅនៅក្នុងប្រធានបទនីមួយៗដែលយើងជ្រើសរើស ដើម្បីចិញ្ចឹមគេឲ្យគេភ្លឺស្វាង។ ១០ឆ្នាំកន្លងមកយើងទីពឹងនៅក្នុងសៀវភៅដែលយើងរៀបចំនៅជំនាន់ទី១ សម្រាប់ជំនាន់ទី២នេះដែលចាប់ផ្ដើមពីថ្ងៃស្អែកតទៅ យើងធ្វើសៀវភៅថ្មី។ យើងមើលឥឡូវនេះ កូនក្មេងគេប្រែប្រួលហើយ របៀបដែលយើងធ្វើប្រែប្រួលហើយ យើងត្រូវអប់រំយ៉ាងម៉េចឲ្យគេចាប់អារម្មណ៍ថែមទៀត។ ហេតុនេះហើយសព្វថ្ងៃយើងអត់ដឹងទេ ប៉ុន្តែគេកំពុងរៀបចំគ្រប់ឧបករណ៍សម្ភារអ្វីទាំងអស់ថ្មីៗ ដើម្បីស៊ីនឹងការលូតលាស់នេះ។ ដូច្នេះ យុវជនយុវនារីចូលទៅក្នុងពិភពថ្មី យុវជន១០ឆ្នាំ យើងត្រូវការចូលយ៉ាងជ្រៅទៅក្នុងឱកាសអប់រំ អប់រំចិត្ត អប់រំផ្លូវវិញ្ញាណ ដើម្បីឲ្យយុវជនរឹងមាំនៅក្នុងជីវិតរបស់ពួកគេ។ ឲ្យយើងមានឯកសារយ៉ាងច្បាស់លាស់ដើម្បីណែនាំប្រជុំយុវជន សព្វថ្ងៃពេលប្រជុំគេអត់ដឹងធ្វើអ្វី អត់ដឹងរៀបចំអ្វីខ្លះ? ដូច្នេះ មួយខែម្ដងឲ្យយើងមានឯកសារមួយច្បាស់លាស់មានប្រធានបទមួយ មានព្រះបន្ទូលជួយយើងបំភ្លឺជីវិត។ មេក្រុមយុវជនចេះដឹងនាំ ដោយសារគេគិតអំពីសង្គមខ្ញុំយ៉ាងម៉េចសព្វថ្ងៃ? ខ្ញុំមានតួនាទីអ្វីខ្លះ? និងព្រះពន្ទូលរបស់ព្រះជាម្ចាស់បំភ្លឺខ្ញុំ

យ៉ាងម៉េច? ឧបករណ៍យើងមានច្រើនហើយ សមត្ថភាពយើងមានច្រើនហើយ យើងមានរៀបចំកាលវិភាគ មានតារាង និងសម្ភារ អប់រំនិងអប់រំ ផ្លូវកាយ ផ្លូវចិត្ត និងផ្លូវវិញ្ញាណ ដើម្បីស្គាល់ជីវិតនៅក្នុងសង្គម ដើម្បីស្គាល់ពិភពលោក។ យើងត្រូវការណែនាំឲ្យយុវជនយើង ទទួលការអប់រំ ដើម្បីមានសមត្ថភាពដាក់សំណួរ ដើម្បីឲ្យយុវជនមានសមត្ថភាពទទួលខុសនិងត្រូវ និងចូលរួមយ៉ាងសកម្មទៅក្នុងពិភពដែលកំពុងកើតឡើង។ នេះជាបេសកកម្មដែលយើងទទួល ឲ្យយើងគិតថា១០ឆ្នាំទៀត នៅពេលដែលយើងចាប់ផ្ដើមទៅជាចាស់ហើយ យើងបានជួយមួយចំនួនដើម្បីឲ្យព្រះសហាគមន៍ខ្ញុំ និងប្រទេសខ្ញុំរីកចម្រើន ហើយខ្ញុំសប្បាយចិត្តណាស់។

យើងអរព្រះគុណព្រះជាម្ចាស់ ហើយសូមព្រះអង្គជួយយើង ដើម្បីឲ្យយើងបន្តទទួលកម្លាំងពីប្រភពនៃជីវិតគឺព្រះយេស៊ូផ្ទាល់។ ការិយាល័យយុវជន បីដូចជាការិយាល័យទាំងអស់មានជីវិតអាចទៅមុខ ដោយសារមូលហេតុតែមួយ គឺព្រះយេស៊ូដែលជាផ្លូវ ជាសេចក្ដីពិត និងជាជីវិត។ អាម៉ែន៕